**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង

រវាងរោងចក្រ ញូ វ៉ាយដ៍(ខេមបូឌា)ហ្វាមេន នឹង សហជីប តំណាងកម្មករនិយោជិកប្រចាំរោងចក្រ។ ឆ្នាំពីរពាន់ម្ភៃបី ខែមករា ថ្ងៃទីដប់បី វេលាម៉ោងប្រាំបួនគត់នៅក្រុមហ៊ុន ញូ វ៉ាយដ៍ ដែលមានអាសយដ្ឋានស្ថិតនៅភូមិ ទួលពង្រ សង្កាត់ ចោមចៅ ខណ្ឌ ពោធិ៍សែនជ័យ រាជធានីភ្នំពេញ មានបើកកិច្ចប្រជុំជាមួយថ្នាក់ដឹកនាំសហជីពមូលដ្ឋាន ប្រតិភូបុគ្គលិក និងតំណាងនិយោជកនៃក្រុមហ៊ុន ស្តីពីករណីក្រុមហ៊ុនស្នើ សុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១០០៥ នាក់ (ស្រី៧៩២នាក់) ក្នុងចំណោមកម្មករនិយោជិតសរុប ១០០៥ នាក់(ស្រី៧៩២)។ (ប្រាក់ឈ្នួលនឹងបើកថ្ងៃទី០៨ខែកុម្ភៈឆ្នាំ២០២៣) ដោយមូលហេតុក្រុមហ៊ុនជួបប្រទះនូវផលវិបាកផ្នែកសេដ្ឋកិច្ចគ្មានអ្នកបញ្ជាទិញគ្រប់គ្រាន់។

សមាសភាពចូលរួមក្នុងកិច្ចប្រជុំ៖

**ក-តំណាងនិយោជក**

-លោក. LIAO CHUNG TE នាយកក្រុមហ៊ុន

-លោក. ស៊ីម សោភ័ណ្ឌ ប្រធានរដ្ឋបាល និងជាអ្នកបកប្រែ

**ខ-តំណាងសហជីព ប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុន**

-សហជីព កម្មករកម្ពុជា លោក ប៉ុក ហាវ

-សហជីព យុវជនខ្មែរ អ្នកស្រី ងួន ពៅ

-សហជីព កម្មករនិយោជិត លោក យឹម ប៊ុនធឿន

-សហជីព ឯករាជ្យការពារកម្មករ លោក ឆុង ឈន

-ប្រតិភូបុគ្គលិក លោក ឆាយ សុភាន

-ប្រតិភូបុគ្គលិក អ្នកស្រី ស្រី បូរ៉ា

-ប្រតិភូបុគ្គលិក អ្នកស្រី ង៉ែត ចំរើន

-ប្រតិភូបុគ្គលិក អ្នកស្រី សម្បត្តិស្រីឡា

-ប្រតិភូបុគ្គលិក អ្នកស្រី ប្រាក់ ឡា

-ប្រតិភូបុគ្គលិក អ្នកស្រី ជា សារឿន

-ប្រតិភូបុគ្គលិក អ្នកស្រី ម៉ៃ ណាគ្រី

ជាកិច្ចចាប់ផ្តើម លោក LIAO CHUNG TE.នាយកក្រុមហ៊ុន និងជាប្រធានអង្គប្រជុំបានថ្លែងអំណរគុណដល់ លោក លោកស្រី ជាថ្នាក់ដឹកនាំសហជីពមូលដ្ឋាន និងជាប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុនទាំងអស់ដែលបានអញ្ជើញ ចូលរួមក្នុងកិច្ចប្រជុំនេះ។ទន្ទឹមនឹងនេះ ផ្អែកតាមរបៀបវារៈនៃអង្គប្រជុំគឺគណៈគ្រប់គ្រងក្រុមហ៊ុនសម្រេចរៀបចំសំណើរ ទៅអធិការការងារដើម្បីព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១០០៥នាក់ (ស្រី៧៩២នាក់) (ក្នុងនោះផ្អែកដេរចំនួន

៦១០នាក់ ផ្នែកតុកាត់ចំនួន ៦៣ នាក់ ផ្នែកឃ្លាំង ២៧ នាក់ ផ្នែក ពិនិត្យ៨៤ នាក់ ផ្នែកវេចខ្ចប់ ៧៩នាក់ ផ្នែកអ៊ុត៣៩ នាក់ ផ្នែកដេរកំរូ២០នាក់ ផ្នែកពិនិត្យគុណភាព ២០នាក់ ផ្នែកអនាម័យ១១នាក់ ផ្នែកជាងម៉ាស៊ីន១២នាក់ ចុងភៅ៣ នាក់ ផ្នែកការិយាល័យ៣៦នាក់) លើកម្មករនិយោជិតសរុបចំនួន ១០០៥ នាក់(ស្រី៧៩២នាក់) ក្នុងរយៈពេល ៥៩ ថ្ងៃ ចាប់ពី ថ្ងៃទី ០១ ខែ កុម្ភៈឆ្នាំ២០២៣ ដល់ថ្ងៃទី ៣១ ខែ មីនាឆ្នាំ២០២៣ ដោយហេតុថាក្រុមហ៊ុនជួបប្រទះនូវផលវិបាកផ្នែកសេដ្ឋកិច្ចគ្មានអ្នកបញ្ជាទិញគ្រប់គ្រាន់។

ផ្អែកតាមបញ្ហាខាងលើ លោកនាយកបានស្នើសុំឲ្យលោក លោកស្រីទាំងអស់ដែលជាតំណាងឲ្យកម្មករនិយោជិត មានការយោគយល់ និងសម្បទានចំពោះក្រុមហ៊ុនក្នុងគ្រាលំបាកនេះដើម្បីទុកឱកាសឲ្យក្រុមហ៊ុនបន្តស្វែងរកអ្នកបញ្ជាទិញជាបន្តទៀតដើម្បីធានានូវស្ថិរភាពច្រវាក់ផលិតកម្មរបស់ក្រុមហ៊ុន។

បន្ទាប់ពីអង្គប្រជុំបានពិគ្រោះយោបល់គ្នាទៅវិញទៅមកក្នុងន័យកិច្ចសហការល្អនៅកន្លែងធ្វើការរួចមក អង្គប្រជុំបានឯកភាពគ្នាជាឯកច្ឆន្ទដូចខាងក្រោម៖

១-ក្នុងអំឡុងពេលក្រុមហ៊ុនព្យួរកិច្ចសន្យាការងារកម្មករចំនួន ១០០៥ នាក់ (ស្រី៧៩២នាក់) រយៈពេល ៥៩ថ្ងៃ ចាប់ពី ថ្ងៃទី០១ខែកុម្ភៈ ឆ្នាំ ២០២៣ ដល់ថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០២៣ តំណាងសហជីព ប្រតិភូបុគ្គលិកដែលជាតំណាងឲ្យកម្មករនិយោជិតទាំងអស់ឯកភាពទទួលយកនូវប្រាក់ឧបត្ថម្ភពីក្រុមហ៊ុនចំនួន៥០ដុល្លាក្នុងមួយខែ។ក្រុមហ៊ុននឹងបើកប្រាក់ឧបត្ថម្ភសរុបចំនួន១០០ដុល្លាសម្រាប់រយៈនៃការព្យួរកិច្ចសន្យាការងារនេះ នៅថ្ងៃទី៣១ខែមករាឆ្នាំ ២០២៣។

២-ក្នុងករណីចាំបាច់ដែលក្រុមហ៊ុនមានអ្នកបញ្ជាទិញគ្រប់គ្រាន់ឡើងវិញនៅមុនកាលកំណត់នៃរយៈពេលព្យួរការងារក្រុមហ៊ុននឹងជូនដំណឹងទៅកម្មករនិយោជិតរយៈពេល១០ថ្ងៃមុនដើម្បីបងប្អូនកម្មករបានចូលធ្វើការជាធម្មតាវិញ។

៣-ភាគីនិយោជក និងភាគីតំណាងសហជីព ប្រតិភូបុគ្គលិក ឯកភាពអនុវត្តតាមខ្លឹមសារនៃកំណត់ហេតុ ព្រមព្រៀងគ្នានេះចំពោះមុខច្បាប់ជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា ឬផ្តិតមេដៃតទៅ។

**បានឃើញ និងឯកភាព**

**ប្រធានអង្គប្រជុំ**

**លេខាកត់ត្រា**

**បានឃើញ និងឯកភាព**

**តំណាងសហជីពមូលដ្ឋាន និងប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុន**